លក្ខន្តិកៈ

នៃ

ពុទ្ធិកសមាគមខ្មែរ

****

ជំពូក 1

គោលបំណង

ប្រការ 1- គោលបំណង នៃសមាគម

1- ដើម្បីអនុវត្តកិច្ចការផ្នែកសាសនា ការអប់រំវប្បធម៌និងផ្នែកសង្គ្រោះ ក្នុងក្របខណ្ឌច្បាប់ពន្ធដារឆ្នាំ 1954 ។ ដោយគោលដៅតាមគោលបំណងខាងលើនេះ ពុទ្ធិកសមាគមខ្មែរនឹងបង្កើតទីកន្លែងមួយ មានឈ្មោះ "ពុទ្ធិការាម" សម្រាប់បើកផ្សាយពុទ្ធសាសនាផ្នែកទស្សនវិជ្ជា វប្បធម៌ និងសង្គមកិច្ច ។ ដោយពិសេស ពុទ្ធិកសមាគមខ្មែរ នឹង :-

- ក - រៀបចំកិច្ចប្រជុំប្រកបជនដែលចាប់អារម្មណ៍ចំពោះពុទ្ធសាសនា និង ពុទ្ធិកវប្បធម៌
- ខ - រៀបចំពិធីពុទ្ធសាសនា
- គ - រៀបចំពុទ្ធិកបណ្ណាល័យ
- ឃ - ផ្ដល់ទីកន្លែង និងសម្ភារៈសម្រាប់អប់រំកម្មដ្ឋាន និងធ្វើពិធីបុណ្យផ្សេងៗតាមផ្លូវពុទ្ធសាសនា
- ង - ស្រាវជ្រាវ និងផ្សព្វផ្សាយនូវពត៌មានផ្សេងៗដែលទាក់ទងជាមួយពុទ្ធសាសនា និងពុទ្ធិកវប្បធម៌

2- ដើម្បីរកនិងទទួលជាម្ចាស់កម្មសិទ្ធិ ដើម្បីថែរក្សាគ្រប់គ្រងនិងចាត់ចែងនូវទ្រព្យសម្បត្តិជា ចលនវត្ថុក្តី អចលនវត្ថុក្តី ជារូបីក្តី អរូបីក្តី អំពីប្រភពសាធារណៈ ឬឯកជនខាងនានាដោយស្របទៅតាមផ្លូវច្បាប់។

ប្រការ 2- សមាគមនេះ រៀបចំឡើងដោយមានគោលបំណងមិនយកកម្រៃសោះ។ ប្រាក់ចំណេញរបស់សមាគម មិនត្រូវបានជាផលប្រយោជន៍ដល់សមាជិក អភិបាល អ្នកចាត់ការណាមួយរបស់សមាគម ឬឯកជនណាមួយជាដាច់ខាត វៀរលែងតែប្រាក់បំណាច់បន្តិចបន្តួចចំពោះសេវាដែលជាប្រយោជន៍ដល់សមាគម។

ប្រការ 3- សមាជិក អភិបាល និងអ្នកចាត់ការនៃសមាគម ឬឯកជនណាមួយ មិនអាចទទួលទ្រព្យសម្បត្តិសមាគមបានទេ នៅពេលដែលសមាគមរលាយ។